# SIREN : ការវិភាគករណី

**បណ្តាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ**

**គម្រោងអន្តរភ្នាក់ងារសហប្រជាជាតិស្តីពីការជួញដូរមនុស្ស (UNIAP): ដំណាក់កាលទី ៣**

**ភ្នំពេញ កម្ពុជា**

ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០០៧

## ការកេងប្រវ័ញ្ចមកលើជនកម្ពុជា នៅលើសមុទ្រ

**ការមិនសូវមានជម្រើសក្នុងការរកការងារធ្វើនៅក្នុងភូមិកំណើតធ្វើអោយបុរសនិងកុមារាកម្ពុជាជាច្រើនធ្វើចំណាកស្រុកដើម្បី រកការងារធ្វើ បើទោះបីជាគេដឹងថាអាចមានគ្រោះថ្នាក់ក្តី ។**

នៅខែមេសា ឆ្នាំ ២០០៧ មនុស្សមួយក្រុមដែលមានបុរស ១០ នាក់ និងកុមារាម្នាក់ នៅខេត្តកណ្តាល (ពីអាយុពី ១៥ ឆ្នាំដល់ ៣៣ ឆ្នាំ) ត្រូវបាននាំទៅធ្វើការនៅលើទូកនេសាទ ក្នុងប្រទេសថៃ ដោយអ្នករត់ការម្នាក់ នៅក្នុងស្រុករបស់ពួកគេ ។ ពួកគេរស់នៅក្នុងភូមិមួយនៅក្នុងស្រុកស្អាង នាខេត្តកណ្តាល យុវជននៅក្នុងភូមិមិនសូវមានអ្វីធ្វើក្រៅតែពីរបរនេសាទទេ ។ មុខរបរនេះមិនសូវល្អប៉ុន្មាន ទេក្នុងពេលឥឡូវនេះ សម្រាប់ជីវភាពរបស់ពួកគេ ដោយសារមច្ឆាជាតិនៅតាមបឹងបួរធម្មជាតិកាន់តែហោចទៅៗ ព្រោះថាមនុស្សកាន់តែកើនចំនួនឡើងជាលំដាប់។ ម្យ៉ាងវិញទៀត គោលនយោបាយដែលចេញក្នុងពេលថ្មីៗនេះ ក្នុងការហាមប្រាមការចិញ្ចឹមត្រីឆ្តោរ ។ មួយវិញទៀត ក្នុងអំឡុងខែមេសា ដែលជាខែទឹកស្រកខ្លាំងផងនោះ បុរសៗមានភារៈជាមេគ្រួសារគ្មានអ្វីធ្វើដើម្បីចិញ្ចឹមខ្លួននិងគ្រួសាររបស់គេឡើយ ។




ការស្វែងរកការងារធ្វើ នៅក្រៅខេត្តរបស់ខ្លួនក៏មិនប្រាកដថាងាយសម្រាប់បុរសទាំងនោះដែរ។ ការងារតាមរោងចក្រពិបាករកណាស់ ដោយសារថៅកែចង់បានកម្មករស្រីជាង ពីព្រោះស្រីៗមិនសូវទាមទារសិទ្ធិច្រើននៅកន្លែងការងារ ។ ទោះបីជាគេធ្លាប់លឺរឿងខ្លះៗស្តីពីការកេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរ នៅលើទូកនេសាទថៃក្តី តែអ្វីដែលគេបានលឺនោះហាក់ ដូចជាតិចតួចពេកណាស់។ មានបុរសចេញទៅថៃ ហើយបាត់ដំណឹងសូន្យឈឹង គេ

សន្មត់ថា អ្នកទាំងនោះទទួលបានការងារធ្វើដោយជោគជ័យ ហើយគ្មានបញ្ហាអ្វីសម្រាប់ផ្តល់ដំណឹងដល់មកអ្នកផ្ទះវិញដែរ។ កត្តាទាំងនេះហើយទើបនាំឱ្យបុរសទាំង ១១ នាក់នៅខេត្តកណ្តាលមានចំណាប់អារម្មណ៍ជាមួយសំដីរបស់អ្នករត់ការនោះ។

**សម្គាល់ :** ពីខេត្តកណ្តាល ក្រុមនោះត្រូវបានគេនាំមកភ្នំពេញ (A) រួចហើយបញ្ជូនទៅច្រកប៉ោយប៉ែត (B)។ ពីប៉ោយប៉ែត គេដើរពេញមួយយប់ឆ្លងកាត់ព្រំដែនដោយគ្មានក្រដាសស្នាម ។ នៅខាងក្នុងទឹកដីថៃ ឡានពីរគ្រឿង និងអ្នកបើកបររង់ចាំពួកគេដើម្បីដឹកពួកគេទៅកាន់សុងខ្លា (Songkhla) ។

ដោយដើរឆ្លងកាត់ព្រំដែនដោយលួចលាក់ បុរសទាំង ១១ នាក់នោះបានដើរពេញមួយយប់ ដើម្បីទៅដល់កន្លែងណាត់ តាមការណែនាំរបស់អ្នករត់ការនៅប៉ោយប៉ែត ។ ឡានបានដឹកពួកគេទៅកាន់សុងខ្លា បន្ទាប់មកពួកគេត្រូវបញ្ជូនឡើងលើនាវានេសាទ។ ទោះបីជាពួកគេបានលឺរឿងធ្វើបាបនៅលើទូកនេសាទថៃក្តី តែពេលនេះពួកគេហាក់ដូចជាគ្មានការព្រួយបារម្ភចំពោះអ្វីដែលអាចកើតមាននៅពេលខាងមុខឡើយ ព្រោះពួកគេត្រូវបានដាក់ឱ្យនៅ និងធ្វើការក្នុងក្រុមតែមួយ។ សុងខ្លា គឺជាកំពង់ផែសមុទ្រទឹកជ្រៅមួយរបស់ថៃសម្រាប់សំចតទូក ដែលបានចេញទៅលើផ្ទៃសមុទ្រក្នុងរយៈយូរ ។ ថៅកែប្រាប់ពួកគេថាត្រូវធ្វើការនៅលើកប៉ាល់នេសាទរយៈពេលពីរឆ្នាំហើយនឹងទទួលប្រាក់ខែសរុបនៅពេលក្រោយ។

**ចំណុចសំខាន់ៗក្នុងករណី:**

- បុរសចំនួន ១១ នាក់ដែលមានអាយុពី ១៥ ឆ្នាំឡើង ត្រូវបានជ្រើសរើសឱ្យទៅធ្វើការនៅលើទូកនេសាទរបស់ថៃ ។ អ្នកទាំងនេះមកពីខេត្តកណ្តាលនៃប្រទេសកម្ពុជា ។
- ពួកគេធ្វើដំណើរដោយស្ម័គ្រចិត្តទៅកាន់ប្រទេសថៃតាមផ្លូវគោក ហើយចុះទៅធ្វើការនៅលើទូកនៅ Songkhla ដែលគេត្រូវធ្វើការរយៈពេល ២ ឆ្នាំ ។
- ក្រោយពីទ្រាំនឹងការធ្វើបាបនៅលើទូកអស់រយៈពេល ១ ខែមក ហើយដោយមិនប្រាកដថាតើគេនឹងទទួលបានប្រាក់កំរៃឬអត់ចំពោះការងាររបស់គេ ពួកគេអស់សង្ឃឹមយ៉ាងខ្លាំងហើយចង់បកក្រោយ។
- អ្នកទាំងនោះធ្វើឱ្យខូចម៉ាស៊ីនដើម្បីបានមកលើដីគោកវិញ ហើយរត់មកកាន់ប្រទេសកម្ពុជាវិញដោយឱ្យគេចាប់ខ្លួននិងបញ្ជូនមកកម្ពុជាវិញ ។
- មេខ្យល់នៅក្នុងភូមិរបស់គេត្រូវបានចាប់ខ្លួន តែអ្នកជាប់ពាក់ព័ន្ធក្នុងការកេងប្រវ័ញ្ច នៅប្រទេសថៃមិនទទួលការដាក់ទោសឬត្រូវបានស៊ើបអង្កេតទេ។

**យើងមិនដឹងថាអ្នករត់ការនៅកម្ពុជាដឹងដែរឬទេ ចំពោះស្ថានភាពកន្លែងការងារនៅប្រទេសថៃ ដែលពោរពេញទៅដោយការកេងប្រវ័ញ្ច និងធ្វើបាបមនុស្សយ៉ាងខ្លាំងនោះ**

នៅលើកប៉ាល់នេសាទ អ្នកទាំង១១ នាក់ មកពីខេត្តកណ្ដាល ត្រូវបានដាក់ឱ្យធ្វើការជាមួយកម្មករខ្មែរដទៃទៀតដែលសរុបទៅមានគ្នារហូតដល់២៧ នាក់ ជាមួយកម្មករថៃចំនួន ៦ នាក់ និងអ្នកបើកបរជាតិថៃ ។ គេធ្វើការច្រើនម៉ោង ហើយមានពេលដេកតែ២ ម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃៗ ។ គេទទួលម្ហូបអាហារមិនគ្រប់គ្រាន់ ហើយគ្មានថ្នាំព្យាបាលជំងឺទេ ។ មានការជេរស្ដីនិងវាយដំ កើតមានជារឿយៗ ដោយកម្មករថៃខ្លះមានបំពាក់ដោយអាវុធទៀតផង។ កម្មករខ្មែរម្នាក់ជើងរបស់គាត់ហើមហើយពិបាកឈរ ត្រូវបានគេវាយដំនិងបង្ខំអោយធ្វើការជាបន្តទៀត ។ កម្មករទាំងនោះត្រូវបានប្រាប់ដោយកម្មករខ្មែរឯទៀត ដែលកំពុងធ្វើការនៅក្នុងទូកដែលបើកមកជិតថា ទូករបស់គេនោះមានឈ្មោះមិនល្អទេ គឺធ្លាប់លក់ និងបោកកម្មករដោយមិនបើកលុយឱ្យក្រោយពីធ្វើការបាន ២ឆ្នាំ ។ នៅទីបំផុត កម្មករខ្មែរទាំងនេះចាប់ផ្ដើមដឹងខ្លួនថា ពួកខ្លួនត្រូវបានគេលក់ឱ្យធ្វើការនៅលើទូក ។

ក្រោយពីនៅលើទូកបានមួយខែមក គេដឹងថាគេមិនអាចទ្រាំទ្របានរហូតដល់ ២ ឆ្នាំទេ។ គេរកវិធីគេចខ្លួន គេមានមធ្យោបាយដ៏តិចតួចដោយសារពួកគេកំពុងស្ថិតនៅកណ្ដាលមហាសាគរ ។ ពួកគេបានសួរកម្មករខ្មែរក្នុងកប៉ាល់ដទៃទៀតនូវវិធីត្រឡប់មកដីគោកវិញ ។ ពួកគេត្រូវបានប្រាប់ឱ្យរកឧបាយកលដូចជាធ្វើឱ្យម៉ាស៊ីនកប៉ាល់ខូចជាដើមដើម្បីអាចត្រឡប់មកដីគោកវិញ ។ កម្មករក្មេងជាងគេបានប្រើល្បិចធ្វើអោយម៉ាស៊ីនខូច និងសម្រេចប្រកបដោយជោគជ័យក្នុងការធ្វើអោយទូកត្រឡប់ចូលមកឆ្នេរវិញបាន ។ ក្រុមកម្មករបាននិយាយថាការធ្វើបែបនេះគឺជាការប្រថុយបំផុត ពីព្រោះបើថៃដឹង គេអាចមានគ្រោះថ្នាក់ដល់ជីវិត ។ តែសំណាងល្អ ពួកថៃមិនដឹងហើយបត់នាវាចូលផែដើម្បីធ្វើការជួសជុល ។

នៅពេលចូលដល់ច្រាំងក្នុងប្រទេសថៃ ពួកគេម្នាក់ៗទទួលបានប្រាក់ ៥០០បាត ហើយត្រូវបានគេប្រាប់អោយនៅក្បែរៗផែនៅពេលទូកទទួលការជួសជុល ។ តែពួកគេចង់តែមកផ្ទះ ហើយខ្លាចគេបញ្ជូនឱ្យចូលទៅធ្វើការក្នុងកប៉ាល់មួយទៀតរបស់ថៅកែដដែលនោះ ។ ពួកគេបានខ្ចីទូរស័ព្ទដៃដើម្បីទាក់ទងមកឪពុកម្ដាយរបស់គេ ។ ឪពុកម្ដាយរបស់គេក៏បានទៅរកអ្នករត់ការ។ ឪពុកម្ដាយរបស់គេត្រូវបានប្រាប់ថា ពួកគេត្រូវបង់ ៣៥០០ បាត (ប្រហែល ១០០ដុល្លា) ក្នុងម្នាក់ៗ ដើម្បីបានត្រឡប់មកផ្ទះវិញ ។ ជាដំបូង ពួកគាត់យល់ព្រមបង់ប្រាក់ក្នុងចំនួននោះមែន តែតំលៃនេះបានកើនដល់ ៦៥០០ បាត ហើយគេមិនមាន លទ្ធភាពក្នុងការរកប្រាក់បង់ទេ ។ ឪពុកម្ដាយបានប្រាប់ពីរឿងនេះដល់កូនៗរបស់គាត់នៅឯនាយ។ ហើយ មេខ្យល់បានប្រាប់គាត់ថា យុវជនទាំងនោះនឹងត្រូវចាប់ខ្លួនបើពួកគាត់មិនព្រមបង់ប្រាក់ទេនោះ ។

**ជម្រើសមួយដែលប្រសើរបំផុតរបស់គេដើម្បីអាចត្រឡប់មកផ្ទះវិញ គឺឱ្យសមត្ថកិច្ចគេចាប់ខ្លួន និងបញ្ជូនមកមាតុប្រទេសវិញ**

គ្រួសាររបស់កម្មករបានទាក់ទងទៅអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា គឺអង្គការ LICADHO និង LSCW ដែលតាមដានស្ថានភាពរបស់ក្រុមកម្មករនោះតាមរយៈបណ្តាញរបស់គេ នៅប្រទេសថៃ ។ អង្គការទាំងនេះក៏បានរាយការណ៍ជូនផងដែរពីករណីនេះទៅដល់នាយប៉ុស្តិ៍នគរបាលប្រចាំឃុំ ហើយបន្ទាប់មកទៀតនាយប៉ុស្តិ៍ក៏បានរាយការណ៍ជូនដល់ថ្នាក់លើរបស់គាត់អំពីករណីនេះតាមរយៈស្នងការនគរបាលខេត្ត ជាបន្តទៀត ។

នៅប្រទេសថៃ ក្រោយពីបានដឹងថាឪពុកម្តាយមិនអាចមានប្រាក់បង់ឱ្យអ្នករត់ការនោះ ក្រុមកម្មករក៏គិតពីជំរើសផ្សេង ដោយសំរេចថាការឱ្យសមត្ថកិច្ចចាប់ខ្លួនបញ្ជូនមកប្រទេសវិញគឺជាវិធីដែលអស់លុយតិចបំផុត លឿនបំផុត និងសុវត្ថិភាពបំផុត ។ ដូច្នេះ គេបានប្រគល់ខ្លួនឱ្យនគរបាល ហើយត្រូវបានឃុំខ្លួនមួយរយៈនៅ ស្តៅ (Sadao) នៅតំបន់សុងខ្លា បន្ទាប់មក ត្រូវបានបញ្ជូនដោយមន្ត្រីអន្តោប្រវេសន៍មកកាន់ច្រកព្រំដែនប៉ោយប៉ែត ជាទីដែលគ្រួសាររបស់គេទៅចាំទទួលពួកគេមកផ្ទះវិញ ។ អ្នករត់ការនៅខេត្តកណ្តាលត្រូវបានចាប់ខ្លួន ហើយកំពុងរង់ចាំការកាត់ទោស ។ តែអ្នកភូមិជាច្រើនមិនដឹងជាប្រាកដថាតើអ្នករត់ការនោះដឹងពីស្ថានភាពរបស់កម្មករទាំងនោះនៅប្រទេសថៃដែរឬទេ ។ ថៅកែនិងអ្នករត់ការនៅប្រទេសថៃមិនបានទទួលការដាក់ពិន័យឬស៊ើបអង្កេតទេ ។

តើនេះជាការជួញដូរមនុស្សដែរឬទេ? បើករណីនេះជាការជួញដូរមនុស្ស តើនរណាជាជនល្មើសដែលគួរយកមកកាត់ទោស? នៅកន្លែងគោលដៅម្ខាងទៀត បរិយាកាសការងារនៅលើនាវានេសាទមានលក្ខណៈរំលោភបំពានដែលធ្វើឱ្យបុរសទាំងនេះចង់បោះបង់ការងារចោល តែពួកគេមិនអាចទៅណាបានទេដោយហេតុថា ខ្លួនកំពុងរស់នៅ និងធ្វើការនៅលើទូកកំពុងបណ្តែតខ្លួននៅលើមហាសាគរដ៏ធំល្វឹងល្វើយ ។ ផ្ទុយទៅវិញមិនទាន់មានការកំណត់បានច្បាស់ថាអ្នករត់ការ នៅខាងកម្ពុជាដែលត្រូវបានចាប់ខ្លួននោះ ដឹងពីការធ្វើបាបពលករនៅលើទូកនេសាទថៃ ។ គាត់ស្គាល់អ្នករត់ការ/ជនជួញដូរមនុស្ស នៅខាងភាគីថៃដែរឬទេ ឬក៏ប្រហែលជាគេមិនដឹងថាកម្មករខ្មែរទាំងនោះនឹងត្រូវទៅនៅកន្លែងណានោះទេ ។ ដោយសារយន្តការនិងការទំនាក់ទំនងរវាងអ្នករត់ការមានភាពមិនច្បាស់ ហើយមិនទាន់ត្រូវបានអង្កេតនៅឡើយទេនោះ គេអាចនិយាយបានថា នេះជាករណីនៃការកេងប្រវ័ញ្ចកំលាំងពលកម្ម ហើយវាជាការទទួលខុសត្រូវរបស់អ្នកបើនាវានៅលើនាវាខាងថៃនិងប្រហែលជាថៅកែផងដែរ ។ ប៉ុន្តែមានការពិបាកយល់ពីការពាក់ព័ន្ធរបស់អ្នករត់ការនិងអ្នកដឹកជញ្ជូនដទៃទៀតក្នុងបទល្មើស[១] នេះ ។ ជាធម្មតាការកេង

ប្រវញ្ចជនរងគ្រោះជាបុរសទាំងនេះ ទាមទារ និងត្រូវទទួលបានការជួយធ្វើអន្តរាគមន៍ ។ ករណីនេះបង្ហាញអោយឃើញយ៉ាងច្បាស់ពីសារៈសំខាន់នៃការធ្វើអោយច្បាប់ជាតិមានភាពស្របគ្នានឹងពិធីសារក្រុងប៉ាលែរម៉ូ (Palermo) ។

**ការទប់ស្កាត់ គោលនយោបាយ ការការពារ និងការយកមកកាត់ទោស នៅពេលយើងមើលចំណុចទាំងអស់នេះក្នុងការប្រឆាំងនឹងការជួញដូរ តើអ្វីដែលចាំបាច់ធ្វើចំពោះមនុស្សដែលរងការកេងប្រវ័ញ្ចតាមរបៀបនេះ?**

ការកើនឡើងសេចក្តីត្រូវការសម្រាប់ជីវភាព និងសម្ពាធបរិស្ថានក្នុងជីវភាពរស់នៅក្នុងភូមិនេសាទតាមបែបបុរាណនៅកម្ពុជា ដូចជាភូមិទាំងឡាយនៅខេត្តកណ្តាលនេះ បណ្តាលឱ្យមនុស្សម្នាភ័យខ្លាចថាស្ថានភាពអវិជ្ជមានទាំងនេះនាំឱ្យមានចំណាកស្រុកគ្មានសុវត្ថិភាពកាន់តែច្រើន ដោយសារបុរស និងក្មេងប្រុសទៅរកការងារធ្វើនៅកន្លែងផ្សេងទៀត។ ដោយសារការ គ្មានដីស្រែចម្ការសម្រាប់ធ្វើកសិកម្ម ត្រីកាន់តែខ្សត់ និងពិបាករកការងារតាមរោងចក្របាននោះ ទើបធ្វើឱ្យអ្នកនេសាទនៅជនបទដែលមានចំណេះដឹងតិចតួច ឬមិនស្គាល់ទីក្រុងមិនមានឱកាសច្រើនទេក្នុងការទទួលបានការងារធ្វើនោះ ។ ក្នុងការពិភាក្សាជាក្រុមនៅក្នុងភូមិស្តីពីមនុស្សប្រុសទាំង ១១នាក់នោះ បុរសក្មេងៗភាគច្រើន នៅក្នុងភូមិនិយាយថា ក្រោយពីបានឮរឿងរបស់អ្នកទាំងនោះ មិនហ៊ានប្រថុយទៅធ្វើការតាមទូកនេសាទ នៅប្រទេសថៃទេ។ តែគេត្រូវការ ការងារនៅក្រៅភូមិជាខ្លាំង ទោះបីការងារអ្វីក៏ដោយ ។ ដូច្នេះ គ្រាន់តែអ្នករត់ការឬអ្នកជិតខាងនិយាយបញ្ចុះបញ្ចូលតែបន្តិចពួកគេឆាប់សម្រេចចិត្តចាកចេញហើយ ដោយសួរនាំ ឬមានកង្វល់តែបន្តិចបន្តួចចំពោះការងារ និងការធ្វើដំណើរ ។

---

(១) ការរំលោភបំពានធ្ងន់ធ្ងរពីសំណាក់អ្នកទទួលខុសត្រូវ និងថៅកែទូកគួរត្រូវតែទទួលការកាត់ទោសពីបទឧក្រិដ្ឋ និងការការពារជនស៊ីវិល តាមរយៈច្បាប់ការពារពលករ ។

## អនុសាសន៍

| បញ្ហាដែលត្រូវបានកំណត់ | | អនុសាសន៍ |
|---|---|---|
| ១ | កន្លងមកមានការស្រាវជ្រាវមិនច្រើនទេ ពីលក្ខខ័ណ្ឌការងារកេងប្រវ័ញ្ចនៅតាមទូកនេសាទ និងមានការដាក់ទោសតិចតួចទៅលើម្ចាស់ទូកឬមេការនៅលើទូក ។ | ១) គួរមានការដាក់ទោសសមល្មមដើម្បីកុំឱ្យមានការធ្វើបាបនៅកន្លែងការងារដូចនេះទៀត ។<br>២) គួរមានគោលនយោបាយធ្វើសហប្រតិបត្តិការគ្នារវាងមន្ត្រីអនុវត្តច្បាប់តាមព្រំដែនទាំងសងខាងដើម្បីធ្វើការស៊ើបអង្កេត និងយកមកកាត់ទោសនូវអ្នកដែលទទួលខុសត្រូវចំពោះការ រំលោភបំពាន ។ |
| ២ | ដោយសារនៅតាមភូមិ មិនសូវមានការងារធ្វើច្រើន បុរសចេញទៅរកការងារធ្វើនៅកន្លែងផ្សេង ដែលពេលខ្លះនាំអោយមានការកេងប្រវ័ញ្ច ។ | ១) ការជំរុញការធ្វើចំណាកដោយសុវត្ថិភាពក្នុងសហគមន៍ គួរ ធ្វើឱ្យអ្នកធ្វើចំណាកស្រុកយល់ពីគ្រោះថ្នាក់ដែលអាចមានចំពោះ គេនៅតាមទូកនេសាទ និងអ្វីដែលគេអាចធ្វើបានដើម្បីការពារខ្លួនគេ ។ គួរមានគោលការណ៏ណែនាំចំពោះអ្នកភ្នាក់ងារជ្រើសរើសពលករទៅធ្វើការនៅបរទេស ។ គោលការណ៏នេះគួរមាន ភាពសមស្រប នឹងសារស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ។<br>២) គួរធ្វើឱ្យមានការងារផ្សេងៗសំរាប់ធ្វើនៅក្នុងភូមិ ។ |
| ៣ | កម្មករដែលត្រូវបានគេកេងប្រវ័ញ្ចជួនកាលត្រូវ សមត្ថកិច្ចចាប់ឃុំខ្លួនមុនពេលត្រូវបានបញ្ជូនត្រឡប់វិញ ព្រោះមិនមានប្រព័ន្ធបញ្ជូនសម្រាប់ជួយគេទេ ។ | ត្រូវមានប្រព័ន្ធបញ្ជូននៅក្នុងប្រទេសគោលដៅ ដើម្បីធានាថា អ្នកដែលរងការកេងប្រវ័ញ្ច ការធ្វើបាប និងមិនទទួលបានប្រាក់ កម្រៃពីការងារនៅលើទូកនេសាទ ដឹងពីសិទ្ធិរបស់គេនិងអ្វីដែល គេអាចធ្វើបាន ដើម្បីដោះស្រាយស្ថានភាពរបស់គេ ។ |

### *កំណត់សំគាល់ពីវិធីសាស្ត្រ*

- *ការតាមដាននិងចងក្រងឯកសារលើករណីដោយអង្គការ LSCW និងងអង្គការ LICADHO*
- *ការតាមដាននិងសម្ភាសន៍ជាមួយអ្នកធ្វើមាតុភូមិនិវត្តន៍ដោយអង្គការ UNIAP ជាមួយក្រុមការងារផ្តោតលើក្រុមជនងាយរងគ្រោះ,សមាជិកសហគមន៍, ការសម្ភាសន៍ស៊ីជំរៅជាមួយនគរបាល ប្រធានភូមិ និងអ្នករត់ការ ។*

**អំពីអ្នកនិពន្ធ**

**អង្គការ ទ្រទ្រង់ផ្នែកច្បាប់សម្រាប់កុមារនិងស្ត្រី LSCW និងអង្គការសម្ព័ន្ធដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្សកម្ពុជា LICADHO បានចងក្រងឯកសារលើករណីដទៃទៀតដែលប្រហាក់ប្រហែលនឹង ករណី នេះ ហើយជួយពលករចំណាកស្រុកកម្ពុជាដែលរងការកេងប្រវ័ញ្ច ។**

ចំពោះសំណួរ មតិ និងពតិមានត្រឡប់ស្តីពី SIREN សូមទាក់ទង Paul Buckley តាមអ៊ីម៉ែល paul.buckley@undp.org

---

UNIAP: www.no-trafficking.org

ការបោះពុម្ពព័តិមាននៅក្នុងឯកសារនេះមិនមែនជាការទទួលស្គាល់ផ្លូវការឬការយល់ព្រមរបស់គម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិស្តីពីការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ។ ទស្សនៈ មតិនិងភាពត្រឹមត្រូវនៃខ្លឹមសារដែលមានគឺជាការទទួលខុសត្រូវរបស់ប្រភពដើមតែប៉ុណ្ណោះ ។